២០.៦.២០១៤

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាឧទ្ធរណ៍ភ្នំពេញ**

**សំណុំរឿងព្រហ្មទណ្ឌ**

លេខ : ៤៣៤/ ២២-០៦-២០១០

**សាលដីកា**

លេខ : ៣៦ ក្រ III ច /១៦-០៦-២០១១

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាឧទ្ធរណ៍ភ្នំពេញ**

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ដែលប្រកាស ឱ្យប្រើតាមក្រិត្យលេខ ០៦ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១១ ដោយមានសមាសភាពដូចខាងក្រោម :

**ក្រុមប្រឹក្សាជំនុំជម្រះ**

- លោកស្រី [redacted] ជាប្រធាន
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

- លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

- លោកស្រី [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃសំណុំរឿងព្រហ្មទណ្ឌ លេខ៤៣៤ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១០ រវាង:

១- **ជនជាប់ចោទ** ឈ្មោះ [redacted] ទី ភេទប្រុស អាយុ២២ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃនៅស្នាក់នៅការដ្ឋានសំណង់ [redacted] ាង ខណ្ឌទួលគោក រាជធានីភ្នំពេញ មុខរបរកម្មករសំណង់ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] "រ" នៅលីវ ទោសពីមុនគ្មាន ។

ចាប់ខ្លួនថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០០៩ និងឃុំខ្លួនតាមដីកាលេខ៩៨២ តព្រ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៩។

២- **ជនជាប់ចោទ** ឈ្មោះ [redacted] ថន ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃនៅស្នាក់នៅការដ្ឋានសំណង់ [redacted] ខណ្ឌទួលគោក រាជធានីភ្នំពេញ មុខរបរកម្មករសំណង់ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "រ" នៅលីវ ទោសពីមុនគ្មាន ។

ចាប់ខ្លួនថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០០៩ និងឃុំខ្លួនតាមដីកាលេខ៩៨៤ គព្រ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៩ ។

៣- **ជនជាប់ចោទ** ឈ្មោះ [redacted] **កុសល** ហៅ **សុខ** ភេទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃនៅផ្ទះជួល [redacted] ខណ្ឌសែនសុខ រាជធានីភ្នំពេញ មុខរបរជាងក្រឡឹង ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" នៅលីវ ទោសពីមុនគ្មាន ។

ចាប់ខ្លួនថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០០៩ និងឃុំខ្លួនតាមដីកាលេខ៩៨៣ គព្រ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៩ ។

- មេធាវីការពារជនជាប់ចោទឈ្មោះ វិរោចន៍ សុផង់ ។

**ជាប់ចោទពីបទ : មនុស្សឃាតដោយចេតនា** ប្រព្រឹត្តនៅចំណុចមុខផ្ទះលេខ៦៤ ផ្លូវ២៧១ ក្រុម៥២ សង្កាត់បឹងសាឡាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង ឱ្យផ្តន្ទាទោសតាមមាត្រា៥ នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទក្រិដ្ឋ ។

- **ដើមបណ្តឹងរដ្ឋប្បវេណី** ឈ្មោះ [redacted] **កុល** ភេទស្រី អាយុ៤៦ឆ្នាំ ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃនៅផ្ទះជួលលេខ១៤០ ភូមិថ្មី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

## <u>ដំណើររឿងហេតុមានដូចតទៅ:</u>

កាលពីថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០០៩ វេលាម៉ោង២១:៣០ នាទី ជនរងគ្រោះឈ្មោះ [redacted] ចន្ទី និងមិត្តភ័ក្រ្តឈ្មោះ [redacted] **សុភស្ស** បាននាំគ្នាមកអង្គុយលេងនៅចំណុចមុខផ្ទះលេខ៦៤ ផ្លូវ២៧១ ក្រុម៥២ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក ស្រាប់តែឈ្មោះ [redacted] ថន. [redacted] ទី និងឈ្មោះ [redacted] កុសល បាននាំគ្នាដើរមកពីទិសខាងកើតមកហើយក៏មានទំនាស់ជាមួយក្រុមជនរងគ្រោះ ។ ឈ្មោះ [redacted] ចន្ទី និងឈ្មោះ [redacted] សុភ័ស្ស បានយកកំណាត់ឈើក្តារវាយឈ្មោះ [redacted] កុសល បណ្តាលអោយបែកក្បាល រួចជនល្មើសឈ្មោះ [redacted] ថន. [redacted] ទី និងឈ្មោះ [redacted] កុសល បានវាយតប់ទៅក្រុមជនរងគ្រោះវិញ បណ្តាលឱ្យឈ្មោះ [redacted] ចន្ទី ត្រូវស្លាប់ពេលបញ្ជូនដល់មន្ទីរពេទ្យ ។ ជនល្មើសនាំគ្នាគេចចេញពីទីកើតហេតុ និងត្រូវសមត្ថកិច្ចស្រាវជ្រាវចាប់ឃាត់ខ្លួនបាន បន្ទាប់ពីប្រព្រឹត្តបទល្មើសរួចភ្លាមៗ ។

- បានឃើញសាលក្រមព្រហ្មទណ្ឌ លេខ១១៤ កបIV ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៩ របស់តុលាការក្រុងភ្នំពេញ សំរេចដូចតទៅ:

១- ផ្តន្ទាទោស:

ក- ឈ្មោះ [redacted] **ទី** ភេទប្រុស អាយុ២២ឆ្នាំ ជាតិខ្មែរ

ខ- ឈ្មោះ [redacted] **ថន** ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ

គ- ឈ្មោះ [redacted] **កុសល** ហៅ **សុខ** ភេទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរ

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់១០ឆ្នាំ(ដប់ឆ្នាំ)គិតពីថ្ងៃឃុំខ្លួន ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៩។ ពីបទៈ មនុស្សឃាតដោយចេតនា ប្រព្រឹត្តនៅផ្ទះលេខ៦៤ ផ្លូវ២៧១ ក្រុម៥២ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០០៩ តាមមាត្រា៤ នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទក្រិដ្ឋ។

២- វត្ថុតាងមានៈ

ក- ឈើបន្ទះក្តារមួយកំណាត់ប្រវែង០.៨០ម៉ែត្រ។

ខ- ឈើបន្ទះក្តារមួយកំណាត់ប្រវែង០.៥០ម៉ែត្រ។

គ- ឈើបន្ទះក្តារមួយកំណាត់ប្រវែង០.៧០ម៉ែត្រ។

ត្រូវរឹបអូសបំផ្លាញចោល។

៣- បង្គាប់ឱ្យជនជាប់ចោទឈ្មោះ[redacted]ទី.[redacted]កុសល និងឈ្មោះ [redacted]ថន រួមគ្នាសងសំណងចំនួន ១៥លានរៀល (ដប់ប្រាំលានរៀល)ឱ្យទៅឈ្មោះ[redacted]កុល ជាដើមបណ្តឹងរដ្ឋប្បវេណី។ សុំលើសពីនេះ បដិសេធចោល។

៤- សាលក្រមនេះជំនុំជំរះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩ និងប្រកាសជាសាធារណៈថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៩ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ទី.[redacted] ថន.[redacted] កុសល ហៅ សុខ មេធាវីការពារជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

- **បានឃើញ** បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៩ របស់ឈ្មោះ[redacted] កុសល
- **បានឃើញ** របាយការណ៍ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១០ របស់ចៅក្រម
- **បានឃើញ** សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១០

## នាពេលសវនាការ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះបានអានរបាយការណ៍សង្ខេបរឿង**

ជនជាប់ចោទឈ្មោះ [redacted]កុសល ហៅ សុខ (វត្តមាន)

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] កុល (អវត្តមាន)

មេធាវីជនជាប់ចោទឈ្មោះ[redacted]សុផង់ (វត្តមាន)

- ក្រឡាបញ្ជីបានអានចម្លើយរបស់ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី

**តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋាន**

សុំឱ្យក្រុមប្រឹក្សាពិចារណាលើជនជាប់ចោទផង ព្រោះជនរងគ្រោះបានវាយជនជាប់ចោទដែរ។

**មេធាវីធ្វើសេចក្តីសន្និដ្ឋាន**

កូនក្តីរបស់ខ្លួនមិនមានចេតនាវាយទៅលើជនរងគ្រោះទេ ព្រោះជងរងគ្រោះបានវាយទៅលើកូនក្តីរបស់ខ្លួនមុន។ សុំក្រុមប្រឹក្សាកែប្រែបទចោទពីមនុស្សឃាតដោយចេតនាមកបទអំពើហិង្សាវិញ។

### តុលាការជំនុំជម្រះ

- ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
- ក្រោយពីបានពិនិត្យពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

### សំអាងហេតុ

**យល់ឃើញថា**

១- បណ្តឹងឧទ្ធរណ៍លេខ៦៦៧ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៩ របស់ជនជាប់ចោទឈ្មោះ [redacted] កុសល និងសាលក្រម ព្រហ្មទណ្ឌលេខ១១៤ កបIV ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបានយោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២- ជនជាប់ចោទឈ្មោះ [redacted] កុសល បានឆ្លើយបដិសេធថាមិនបានវាយទៅលើជនរងគ្រោះទេ គឺខ្លួនគ្រាន់តែជាអ្នកទៅសួរនាំ ខាងក្រុមជនរងគ្រោះតែត្រូវក្រុមជនរងគ្រោះវាយបណ្តាលឱ្យដួលសន្លប់ ។

៣- តាមចម្លើយសាក្សីនៅកន្លែងកើតហេតុបានបញ្ជាក់ច្បាស់ថា ក្រុមជនជាប់ចោទទាំងបីនាក់ពិតជាបានចូលទៅវាយជនរងគ្រោះ បណ្តាលឱ្យស្លាប់មែន ហើយក៏ពុំមានសាក្សីណាបញ្ជាក់ថាជនជាប់ចោទឈ្មោះ [redacted] កុសល នេះពុំបានវាយទៅលើជនរងគ្រោះដែរ មានតែចម្លើយជនជាប់ចោទទាំងពីរនាក់ដែលថាបក្សពួកខ្លួនឆ្លើយប៉ុណ្ណោះ ។ ហើយក៏គ្មានសាក្សីណាបញ្ជាក់ថាជនជាប់ចោទ [redacted] កុសល ត្រូវគេវាយអោយសន្លប់ដែរ មានតែសាក្សីឃើញជនជាប់ចោទទាំងបីវាយជនរងគ្រោះរួចនាំ គ្នាគេចខ្លួនបាត់ទុកឱ្យជនរងគ្រោះទទួលគ្រោះថ្នាក់ដល់ស្លាប់ ។

៤- ការបដិសេធរបស់ជនជាប់ចោទ គ្មានហេតុផលសំរាប់ឱ្យសាលាឧទ្ធរណ៍លើកអំពីការសំរាលទោសនេះបានឡើយ ។

៥- មានពិរុទ្ធភាព និងភស្តុតាងគ្រប់គ្រាន់លើជនជាប់ចោទ [redacted] កុសល ពីបទ មនុស្សឃាតដោយចេតនា កាលពីថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០០៩ តាមមាត្រា៤ នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ ។

៦- សាលក្រមព្រហ្មទណ្ឌ លេខ១១៤ កបIV ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញបានសំរេចសេចក្តីមានសំអាងហេតុត្រឹមត្រូវតាមអង្គហេតុ និងអង្គច្បាប់ហើយ គប្បីសាលាឧទ្ធរណ៍តំកល់ទុកជាបានការដដែល ។

### ហេតុដូច្នេះ

### វិនិច្ឆ័យសេចក្តី

១- ទទួលបណ្តឹងឧទ្ធរណ៍ លេខ៦៦៧ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៩ របស់ជនជាប់ចោទឈ្មោះ [redacted] កុសល ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយទាស់ និងគតិច្បាប់ ។

២. តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១១៤ កបIV ចុះថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញទុកជាបានការដដែល ។

៣. បន្តការឃុំខ្លួនជនជាប់ចោទឈ្មោះ[redacted]កុសល តាមច្បាប់ ។

៤. សាលដីកានេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១១ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១១ ចំពោះមុខជនជាប់ចោទ មេធាវីការពារជនជាប់ចោទ កំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណី ។

បើកផ្លូវប្ដឹងតវ៉ាក្នុងកំណត់ច្បាប់ ។

សាលដីកានេះ មានអនុភាពតែទៅលើឈ្មោះ[redacted]កុសល ម្នាក់ប៉ុណ្ណោះ ក្រៅពីនេះមិនទាន់មានអនុភាព អនុវត្តនៅឡើយទេ។

សេចក្ដីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុក អនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និងកងកម្លាំងប្រដាប់អាវុធជួយសហការណ៍អនុវត្តសាលដីកានេះ ឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា[redacted] | ហត្ថលេខា [redacted] | ហត្ថលេខា[redacted] |

បានឃើញ
ប្រធានសាលាឧទ្ធរណ៍

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី 20 ខែ 6 ឆ្នាំ 2011
ក្រឡាបញ្ជី

[redacted]